លេខ ៣៤ ចេញផ្សាយថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៤

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែមីនា ឆ្នាំ២០២៤

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ

នាថ្ងៃព្រហស្បតិ៍ ៥ រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ម៉ែន ធីរុទ្ធ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង **លោកស្រី** Alissar Chaker តំណាង UNDP ប្រចាំប្រទេសកម្ពុជា នៅសណ្ឋាគារហៀវហៀល បាយ ម៉ារៀត ភ្នំពេញ។

កិច្ចប្រជុំនេះមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ធនាគារជាតិនៃកម្ពុជា អង្គការជាតិ-អន្តរជាតិ ស្ថាប័នឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀត។

## មាតិកា


- កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានជាតិ ទំព័រទី១
- កម្មវិធីបណ្តុះបណ្តាលស្តីពី យន្តការបរធនបាលកិច្ចនៅកម្ពុជា ទំព័រទី២
- ពិធីសម្ពោធ AREAA Global Cambodia ទំព័រទី២
- កិច្ចប្រជុំផ្សព្វផ្សាយអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង ទំព័រទី២
- កម្មវិធីបណ្តុះបណ្តាលស្តីពី យន្តការបរធនបាលកិច្ចនៅកម្ពុជា ទំព័រទី៣
- កិច្ចប្រជុំរវាងក្រុមការងារបច្ចេកទេសនៃគម្រោង ACSEP សមាសភាគទី១ ទំព័រទី៣
- កិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី១៧ ទំព័រទី៣
- កិច្ចប្រជុំពិភាក្សាការងាររវាង **ន.ប.ធ.** និងសភាពាណិជ្ជកម្មចិន (កម្ពុជា) ទំព័រទី៤
- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង និយ័តករធានារ៉ាប់រងកម្ពុជា និងវិទ្យាស្ថាន ខេមអេដ ទំព័រទី៥
- កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ទំព័រទី៥
- កម្មវិធី "ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល" ទំព័រទី៥
- កម្មវិធី "សប្តាហ៍គាំពារសង្គមកម្ពុជាឆ្នាំ២០២៤" ទំព័រទី៥
- កិច្ចប្រជុំលើកទី៣ នៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ទំព័រទី៦
- ពិធីសំណេះសំណាលអបអរសាទរខួបលើកទី១១៣ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤ ក្រោមប្រធានបទ "ស្ត្រី និងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល" ទំព័រទី៦
- កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ទំព័រទី៦
- សិក្ខាសាលាស្តីពី ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ទំព័រទី៧
- កិច្ចពិភាក្សាការងាររវាង **ន.ប.ធ.** ជាមួយក្រុមហ៊ុនអចលនទ្រព្យ និងក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មានវិទ្យា ទំព័រទី៧
- ពិភាក្សាលើការរៀបចំយន្តការណ៍គន្លឹះ សម្រាប់ជាមូលដ្ឋានរៀបចំសេចក្តីព្រាងឯកសារក្របខណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង ទំព័រទី៨
- កិច្ចប្រជុំលើកទី ៥ នៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ទំព័រទី៨
- សិក្ខាសាលាស្តីពី ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ទំព័រទី៨




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh  www.facebook.com/trustregulatorcambodia  (855) 23 237 888



រូបភាព៖ កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងក្របខ័ណ្ឌគោល-នយោបាយហិរញ្ញប្បទានជាតិ។

## កម្មវិធីបណ្តុះបណ្តាលស្តីពី យន្តការបរធនបាលកិច្ច នៅកម្ពុជា

នាព្រឹក ថ្ងៃសុក្រ ៦រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមជាមួយលោក Gagnon Jean Pierre នាយកប្រតិបត្តិរងនៃធនាគារ ស្កាបនា ភីអិលស៊ី ជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារ ស្កាបនា ភីអិលស៊ី ដែលជាធនាគារទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច។



រូបភាព៖ កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា"។

## ពិធីសម្ពោធ AREAA Global Cambodia

នាថ្ងៃសៅរ៍ ១៥ កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៤ **ឯកឧត្តម ឈឺ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោក រិន វដ្ឋា** អនុប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីសម្ពោធ AREAA Global Cambodia នៅសណ្ឋាគារ Sun and Moon Urban។ កម្មវិធីនេះ មានការចូលរួមពីអ្នកវិនិយោគអចលនទ្រព្យអន្តរជាតិ និងប្រតិភូមកសហរដ្ឋអាមេរិកដែលជាសមាជិករបស់ AREAA Global។




រូបភាព៖ ពិធីសម្ពោធ AREAA Global Cambodia។

## កិច្ចប្រជុំផ្សព្វផ្សាយអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង

ព្រឹកថ្ងៃចន្ទ ៩រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម ឈឺ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំផ្សព្វផ្សាយអនុក្រឹត្យស្តីពី " ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង" ដឹកនាំដោយ **ឯកឧត្តម ទី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**កសហវ**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យអូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីកសហវ និងមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងក្របខណ្ឌ **កសហវ** នៅទីស្តីការ **កសហវ**។



**រូបភាព៖** កិច្ចប្រជុំផ្សព្វផ្សាយអនុក្រឹត្យស្តីពី " ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង"។

## កម្មវិធីបណ្តុះបណ្តាលស្តីពី យន្តការបរធនបាលកិច្ចនៅកម្ពុជា

នារសៀល ថ្ងៃចន្ទ ៨រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមជាមួយលោក **លី ថៃ** អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច នៃធនាគារ អេស៊ីលីដា ភីអិលស៊ី ជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធន-បាលកិច្ចនៅកម្ពុជា" សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាធនាគារទទួលបានការអនុញ្ញាតពី **ន.ប.ធ.** ធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច។ កម្មវិធីបណ្តុះបណ្តាលនេះ មានអ្នកចូលរួមសរុបចំនួន ៣៥០ នាក់ ក្នុងនោះចូលរួមដោយផ្ទាល់ចំនួន ៥២ រូប មកពីទីស្នាក់ការកណ្តាលនិងបណ្តាសាខានៅរាជធានីភ្នំពេញ និងតាមរយៈអនឡាញចំនួន ២៩៨ នាក់ មកពីសាខានៅតាមបណ្តាខេត្តរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។



**រូបភាព៖** កម្មវិធីបណ្តុះបណ្តាលស្តីពី យន្តការបរធនបាលកិច្ចនៅកម្ពុជា។

## កិច្ចប្រជុំរវាងក្រុមការងារបច្ចេកទេសនៃគម្រោង ACSEP សមាសភាគទី១

នារសៀលថ្ងៃចន្ទ ៨រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤ **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការ នៃគម្រោង ACSEP សមាសភាគទី១ បានដឹកនាំកិច្ចប្រជុំរវាងក្រុមការងារបច្ចេកទេសនៃគម្រោង ACSEP សមាសភាគទី១ ដើម្បីជួបពិភាក្សាការងារ និងផ្តល់ព័ត៌មានអំពីសារបានរបស់គម្រោង ACSEP និងពិភាក្សាលើយន្តការនៃការអនុវត្តមូលនិធិធានាឥណទាន (Credit Guarantee Fund-CGF) ជាមួយសាជីវកម្មធានាឥណទានកម្ពុជា (CGCC) តំណាងដោយ **លោក ណូ លីដា** អគ្គនាយករង CGCC និងសហការី នៅទីស្តីការនៃនិយ័តករបរធនបាលកិច្ច។



**រូបភាព៖** កិច្ចប្រជុំរវាងក្រុមការងារបច្ចេកទេសនៃគម្រោង ACSEP សមាសភាគទី១។

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី១៧

នាព្រឹកថ្ងៃអង្គារ ១០ រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានអញ្ជើញចូលរួមការពារសេចក្តីព្រាង "ផែនការអភិវឌ្ឍន៍ស្ថាប័នបច្ចុប្បន្នកម្មសម្រាប់រយៈពេល ១០ឆ្នាំ (២០២១-២០៣០)របស់និយ័តករបរធនបាលកិច្ច" ក្នុងកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១

លើកទី១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ ជាលទ្ធផល អង្គប្រជុំបានអនុម័តលើសេចក្តីព្រាង "ផែនការអភិវឌ្ឍន៍ស្ថាប័ន បច្ចុប្បន្នកម្មសម្រាប់រយៈពេល ១០ ឆ្នាំ (២០២១-២០៣០) របស់និយ័តករបរធនបាលកិច្ច " ដោយស្នើឱ្យជំនាញពិនិត្យបន្ថែមលើអក្ខរាវិរុទ្ធ និងលើចំណុចខ្លះ។




រូបភាព៖ កិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី១៧។

## កិច្ចប្រជុំពិភាក្សាការងាររវាង ន.ប.ធ. និងសភាពាណិជ្ជកម្មចិន (កម្ពុជា)

នាព្រឹកថ្ងៃអង្គារ ១០រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** **ឯកឧត្តម ណី សាគល** អគ្គនាយករង នៃ **ន.ប.ធ.** អមដោយ **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងសហការី បានជួបប្រជុំពិភាក្សាការងារជាមួយសភាពាណិជ្ជកម្មចិន (កម្ពុជា) តំណាងដោយ **លោក** Lin Shiqiang ប្រធានសភាពាណិជ្ជកម្មចិន (កម្ពុជា) អមដោយ **លោក Zhao Jinhui** អនុប្រធានប្រចាំការ និងជាអគ្គលេខាធិការនៃសភាពាណិជ្ជកម្មចិន (កម្ពុជា) និងសហការី នៅទីស្នាក់ការសភាពាណិជ្ជកម្ម ចិន (កម្ពុជា) ក្នុងគោលបំណងដើម្បីពិនិត្យលទ្ធភាពបង្កើតកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌការលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីកាលានុវត្តភាពវិនិយោគ និងជំរុញការចូលរួមក្នុងទីផ្សារបរធនបាលកិច្ចនៅកម្ពុជា។




រូបភាព៖ កិច្ចប្រជុំពិភាក្សាការងាររវាង **ន.ប.ធ.** និងសភាពាណិជ្ជកម្មចិន (កម្ពុជា)។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង និយ័តករធានារ៉ាប់រងកម្ពុជា និងវិទ្យាស្ថាន ខេមអេដ

នាព្រឹកថ្ងៃពុធ ១១រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** បានអញ្ជើញចូលរួមក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង និយ័តករធានារ៉ាប់រងកម្ពុជា និងវិទ្យាស្ថាន ខេមអេដ ស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងការអភិវឌ្ឍធនធានមនុស្ស នៅក្នុងវិស័យធានារ៉ាប់រងនៅព្រះរាជាណាចក្រកម្ពុជា" នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។



រូបភាព៖ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងវិទ្យាស្ថាន ខេមអេដ។

## កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃពុធ ១១រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោកស្រី ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និងសហការី បានចូលរួមកិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ**) តាមប្រព័ន្ធអនឡាញ (Zoom) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីការធានារ៉ាប់រងបន្ត របស់និយ័តករធានារ៉ាប់រងកម្ពុជា។




រូបភាព៖ កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## កម្មវិធី "ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល"

នារសៀលថ្ងៃព្រហស្បតិ៍ ១២រោចខែមាឃ ឆ្នាំថោះបញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤ និយ័តករបរធន-បាលកិច្ច (ន.ប.ធ.) បានរៀបចំកម្មវិធីអបអរសាទរខួបលើកទី១១៣ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៤ ក្រោមប្រធានបទ "ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និង**លោកជំទាវ ខៀ បូរី**។ ជាមួយគ្នានេះ ក៏មានការរៀបចំប្រគល់បាច់ផ្កា វត្ថុអនុស្សាវរីយ៍ និងប្រាក់ឧបត្ថម្ភដែលជាអំណោយដ៏ថ្លៃថ្លារបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ( **អ.ស.ហ.**) ផ្តល់ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីជានារីរបស់ **ន.ប.ធ.** និងពិសារអាហារសាមគ្គីជាមួយគ្នាផងដែរ។




រូបភាព៖ កម្មវិធី "ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល"។

## កម្មវិធី "សប្តាហ៍គាំពារសង្គមកម្ពុជាឆ្នាំ២០២៤"

នាព្រឹកថ្ងៃអង្គារ ៣កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក រិន រដ្ឋា** អនុប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមពិធីបើក "សប្តាហ៍គាំពារសង្គមកម្ពុជាឆ្នាំ២០២៤" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាវេទិកាថ្នាក់ជាតិប្រចាំឆ្នាំ ក្រោមមូលបទ "បន្តកសាងប្រព័ន្ធគាំពារសង្គមដើម្បីចីរភាព និងភាពធន់" នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា។




រូបភាព៖ កម្មវិធី "សប្តាហ៍គាំពារសង្គមកម្ពុជាឆ្នាំ២០២៤"។

## កិច្ចប្រជុំលើកទី៣ នៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា

នាព្រឹកថ្ងៃអង្គារ ៣កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម ណឺ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី៣ នៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណ-នេយ្យករជំនាញកម្ពុជា (**គ.ក.គ.ក**) ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ទិ តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងជាប្រធាន **គ.ក.គ.ក** ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ នៅទីស្ដីការ **កសហវ**។



រូបភាព៖ កិច្ចប្រជុំលើកទី៣ នៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។

## ពិធីសំណេះសំណាលអបអរសាទរខួបលើកទី១១៣ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤ ក្រោមប្រធានបទ "ស្ត្រី និងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល"

នាព្រឹកថ្ងៃពុធ ៤កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោកស្រី វ៉ា ស៊ីម៉ែន** អនុប្រធានការិយាល័យនៃនាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** បានអញ្ជើញចូលរួមពិធីសំណេះសំណាលអបអរសាទរខួបលើកទី១១៣ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤ ក្រោមប្រធានបទ "ស្ត្រី និងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅទីស្ដីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



រូបភាព៖ ពិធីសំណេះសំណាលអបអរសាទរខួបលើកទី១១៣ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤ ក្រោមប្រធានបទ "ស្ត្រី និងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល"។

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃព្រហស្បតិ៍ ៥ កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃក្របខ័ណ្ឌតាមដាន និងវាយតម្លៃនៃសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២៤-២០៣០ សេចក្តីព្រាងផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល (២០២៤-២០២៦) របស់និយ័តករធានារ៉ាប់រងកម្ពុជា និងសេចក្តីព្រាងផែនការសកម្មភាពបីឆ្នាំរំកិល (២០២៤-២០២៦) របស់និយ័តករបរធនបាលកិច្ច ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** អនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



**រូបភាព៖** កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

## សិក្ខាសាលាស្តីពី ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃសុក្រ ៦ កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យកម្ពុជាបានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច និង **លោក ម៉ុក សិទ្ធី** ព្រឹទ្ធបុរសរងនៃសាកលវិទ្យាល័យកម្ពុជា នៅសាកលវិទ្យាល័យកម្ពុជា។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ, និងនិស្សិតនៃសាកលវិទ្យាល័យកម្ពុជា។



**រូបភាព៖** សិក្ខាសាលាស្តីពី ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។

## កិច្ចពិភាក្សាការងាររវាង ន.ប.ធ. ជាមួយក្រុមហ៊ុនអចលនទ្រព្យ និងក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មានវិទ្យា

នាព្រឹកថ្ងៃអង្គារ ១០កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការីបានអញ្ជើញទទួលជួបប្រជុំពិភាក្សាការងារជាមួយ **ឯកឧត្តម ជា គុកហុង** អមដោយតំណាងក្រុមហ៊ុនអចលនទ្រព្យ, ក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មានវិទ្យា និងក្រុមការងារពាក់ព័ន្ធ ដើម្បីពិភាក្សាស្វែងយល់ពីយន្តការបរធនបាលកិច្ច និងកាលានុវត្តភាពពាក់ព័ន្ធក្នុងការចូលរួមចំណែកជំរុញការវិនិយោគ និងដោះស្រាយភាពជាប់គាំងនៃគម្រោងវិនិយោគនៅខេត្តព្រះសីហនុ។



**រូបភាព៖** កិច្ចពិភាក្សាការងាររវាង ន.ប.ធ. ជាមួយក្រុមហ៊ុនអចលនទ្រព្យ និងក្រុមហ៊ុនបច្ចេកវិទ្យាព័ត៌មានវិទ្យា។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ពិភាក្សាលើការរៀបចំយន្តការណ៍គន្លឹះ សម្រាប់ជាមូលដ្ឋានរៀបចំសេចក្តីព្រាងឯកសារក្របខណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង

នាព្រឹកថ្ងៃសុក្រ ១៣កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក ជី គន់នី** ប្រធានការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុនៃនាយកដ្ឋានកិច្ចការទូទៅ បានអញ្ជើញចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) ដើម្បីពិនិត្យ ពិភាក្សាលើការរៀបចំយន្តការណ៍គន្លឹះ សម្រាប់ជាមូលដ្ឋានរៀបចំសេចក្តីព្រាងឯកសារក្របខណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី **កសហវ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងក្របខណ្ឌ **កសហវ** នៅទីស្តីការ **កសហវ**។




**រូបភាព៖** ពិភាក្សាលើការរៀបចំយន្តការណ៍គន្លឹះ សម្រាប់ជាមូលដ្ឋានរៀបចំសេចក្តីព្រាងឯកសារក្របខណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង។

## កិច្ចប្រជុំលើកទី ៥ នៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល

នាព្រឹកថ្ងៃអង្គារ ២រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកនៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល (**គ.ស.ធ.ឌ.**) បានចូលរួមកិច្ចប្រជុំលើកទី ៥ នៃ **គ.ស.ធ.ឌ.** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ស.ធ.ឌ.** លើរបៀបវារៈចំនួន ៥ រួមមាន៖ ១.របាយការណ៍វឌ្ឍនភាពការងាររបស់អគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.**, ២.ការស្នើសុំការអនុម័តលើសេចក្តីព្រាងផែនការសកម្មភាព ៣ ឆ្នាំរំកិល ២០២៤-២០២៦ នៃគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា, ៣.របាយកាណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០២៣ នៃការអនុវត្តផែនការសកម្មភាព ៣ ឆ្នាំរំកិល ២០២៣-២០២៥ របស់គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, ៤.ការវាយតម្លៃតម្រូវការនៃការធ្វើឌីជីថលូបនីយកម្មរបស់សហគ្រាសក្នុងប្រទេសកម្ពុជា, ៥.ការស្នើសុំពិនិត្យកម្រងបទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល។




**រូបភាព៖** កិច្ចប្រជុំលើកទី ៥ នៃគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល។

## សិក្ខាសាលាស្តីពី ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច

នាព្រឹកថ្ងៃសុក្រ ៥ រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាលាភូមិន្ទរដ្ឋបាល បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធន-បាលកិច្ច" ក្រោមអធិបតីភាពរបស់**ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **ឯកឧត្តម សូលី វណ្ណាម៉ុក** នាយករងនៃសាលាភូមិន្ទរដ្ឋបាលនៅសាលាភូមិន្ទរដ្ឋបាល និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ និងជានាយកសាលាភូមិន្ទរដ្ឋបាល។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ និងកម្មសិក្សាការីមន្ត្រីមធ្យម

អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ និងកម្មសិក្សាការីមន្ត្រីមធ្យម ដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ, និងកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ និងកម្មសិក្សាការីមន្ត្រីមធ្យមនៃសាលាភូមិន្ទរដ្ឋបាល។




**រូបភាព៖** សិក្ខាសាលាស្តីពី "ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888